# ព្រះរាជក្រឹត្យ

នស/រកត/០២០២/០៤០

**យើង**

**ព្រះបាទសម្ដេចព្រះ នរោត្ដម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្ដម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** បង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ហៅកាត់ ( គ.ជ.គ.ម ឬ **NCDM** ) ដែលមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| ១- នាយករដ្ឋមន្ត្រី | ប្រធាន |
| ២- ឥស្សរជនជាន់ខ្ពស់មួយរូប | អនុប្រធានទី១ |
| ៣- រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤- រដ្ឋមន្ត្រី ក្រសួងការពារជាតិ | អនុប្រធាន |
| ៥- រដ្ឋមន្ត្រី ទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៦- រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |

៧-រដ្ឋមន្ត្រី ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក
៨-រដ្ឋមន្ត្រី ក្រសួងធនធានទឹក និងឧតុនិយម សមាជិក
៩-រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក
១០-រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម សមាជិក
១១-រដ្ឋមន្ត្រី ក្រសួងសុខាភិបាល សមាជិក
១២-រដ្ឋមន្ត្រី ក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក
១៣-រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក
១៤-រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា សមាជិក
១៥-តំណាង អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ សមាជិក
១៦-តំណាង ប្រធានសមាគមជាតិកាកបាទក្រហមកម្ពុជា សមាជិក
១៧-រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សមាជិក

**មាត្រា២.-** គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ជាស្ថាប័នចំណុះរាជរដ្ឋាភិបាល និងមានភារកិច្ច ដូចតទៅ :

ក- ធ្វើការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន របស់រាជរដ្ឋាភិបាល ភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល សហគមន៍អន្តរជាតិ និងសប្បុរសជនក្នុង ស្រុក ដើម្បីកៀរគរជំនួយសម្រាប់ឆ្លើយតប សង្គ្រោះបន្ទាន់ និងស្តារឡើងវិញ ។

ខ- ផ្តល់យោបល់ជូនរាជរដ្ឋាភិបាល ដាក់ចេញគោលការណ៍ គោលនយោបាយសំខាន់ៗ សេចក្តីប្រកាស ដើម្បីត្រៀមបង្ការ និងគ្រប់គ្រងគ្រោះមហន្តរាយ ព្រមទាំងវិធានការឆ្លើយតបសង្គ្រោះបន្ទាន់ ការធ្វើអន្តរាគមន៍ជម្លៀសប្រជាជនទៅទីសុវត្ថិភាព ។

គ- ផ្សព្វផ្សាយការងារគ្រប់គ្រងគ្រោះមហន្តរាយដល់សហគមន៍ និងពង្រឹងខ្សែបណ្តាយ ពីថ្នាក់ជាតិ ក្រសួង ស្ថាប័នពាក់ព័ន្ធ រហូតដល់ ខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ ព្រមទាំងបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីបង្កើនសមត្ថភាពការងារគ្រប់គ្រងគ្រោះមហន្តរាយ ឱ្យកាន់តែរឹងមាំ និងមានប្រសិទ្ធភាព ។

ឃ- លើកសំណើជូនរាជរដ្ឋាភិបាលអំពីការត្រៀមបម្រុងនូវមូលនិធិ សម្ភារៈ ប្រេងឥន្ធនៈមធ្យោបាយ ធនធានមនុស្ស ដើម្បីត្រៀមបង្ការ និងធ្វើអន្តរាគមន៍ឆ្លើយតបសង្គ្រោះបន្ទាន់ និងស្តារ

ឡើងវិញមុនពេល ក្នុងពេល និងក្រោយពេលកើតមានគ្រោះមហន្តរាយ ដើម្បីភាពម្ចាស់ការជាមុន ។

**មាត្រា៣.–** គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មានអគ្គលេខាធិការដ្ឋានមួយ ដឹកនាំដោយអគ្គលេខាធិការមួយរូប និងអគ្គលេខាធិការរង មួយចំនួន តាមការចាំបាច់ជាជំនួយការ ។

**មាត្រា៤.–** សមាជិកគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវចូលរួមប្រជុំតាមការអញ្ជើញ របស់ប្រធាន ។

**មាត្រា៥.–** ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា៦.–** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីព្រះរាជក្រឹត្យនេះ ចាត់ទុកជានិរាករណ៍ ។

**មាត្រា៧.–** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តព្រះរាជក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ។

**មាត្រា៨.–** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០២*

នស/រកត.០២០២.០០៤៨

លេខ : ៤៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ . ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាវ ឌី ហ៊ាន់**